ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា២៦ មាត្រា២៧ មាត្រា២៨ និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ ស្ទួន នៃអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះ មានគោលបំណងធានាការគ្រប់គ្រងឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ប្រកបដោយប្រសិទ្ធភាពនិងគណនេយ្យភាព ធានានិងលើកទឹកចិត្តការប្រមូលផ្តុំប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ក្នុងន័យជំរុញនវានុវត្តន៍ កំណើនសេដ្ឋកិច្ច និងការកៀរគរចំណូលថវិកាជាតិ និងធានាសន្តិសុខនិងសុវត្ថិភាពរបស់ប្រជាជន។

**មាត្រា២ .-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពី៖

- លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ ការផ្ទេរ និងការដកហូតការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន
- ការត្រួតពិនិត្យនិងការតាមដានការអនុវត្តលិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ។

**មាត្រា៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តន៍ចំពោះរាល់ប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

និយមន័យនៃពាក្យបច្ចេកទេសក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម៖

**ការអនុញ្ញាត** សំដៅដល់ លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ។

**សូហ្វវែរ** សំដៅដល់កម្មវិធីសម្រាប់ធ្វើឱ្យដំណើរការប្រព័ន្ធកុំព្យូទ័រ ឬកម្មវិធីសម្រាប់សម្រួលដល់ការងាររបស់អ្នកប្រើប្រាស់នៅលើកុំព្យូទ័រ កុំព្យូទ័របន្ទះ ទូរស័ព្ទវៃឆ្លាត ឬឧបករណ៍បច្ចេកវិទ្យាផ្សេងទៀត។

**ការផលិត** សំដៅដល់ការបង្កើតផលិតផលសម្រេចដោយបំលែងចេញពីវត្ថុធាតុដើមឬផលិតផលមិនទាន់សម្រេច។

**ការផ្គុំ** សំដៅដល់ការបង្កើតផលិតផលសម្រេចដោយផ្គុំឡើងពីផលិតផលមិនទាន់សម្រេច។

**ការដំឡើង** សំដៅដល់ការរៀបចំដាក់ឱ្យប្រើប្រាស់។

**គ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ** សំដៅដល់សម្ភារៈបរិក្ខារ ឧបករណ៍ គ្រឿងបង្គុំឬបរិយកណ្ឌដែលត្រូវបានផលិតនិង/ឬនាំចេញឬនាំចូលសម្រាប់ប្រើប្រាស់ជាមួយនឹងកុំព្យូទ័រ។

**បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន** សំដៅដល់បច្ចេកវិទ្យា ដែលរួមមានទាំងហាដវែរនិងសូហ្វវែរសម្រាប់ដំណើរការ រក្សាទុក វិភាគនិង/ឬបញ្ជូនទិន្នន័យ ឬព័ត៌មានតាមប្រព័ន្ធទូរគមនាគមន៍។

**មជ្ឈមណ្ឌលទិន្នន័យ** សំដៅដល់ទីតាំងដែលផ្តល់សេវារក្សាទុក ដំណើរការវិភាគ ការពារសុវត្ថិភាពបញ្ជូនទទួលទិន្នន័យនិងសេវាពាក់ព័ន្ធ។

**មាតិកា** សំដៅដល់កម្រងព័ត៌មានឌីជីថលដែលត្រូវបានរក្សាទុក ដំណើរការ ឬផ្សព្វផ្សាយតាមរយៈកុំព្យូទ័រ កុំព្យូទ័របន្ទះ ទូរស័ព្ទឆ្លាត ឬឧបករណ៍បច្ចេកវិទ្យាផ្សេងៗទៀត។

**សេវាអនឡាញ** សំដៅដល់សេវាទាំងឡាយណាដែលត្រូវបានផ្តល់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន លើកលែងតែសេវាល្បែងស៊ីសង។

**ឧបករណ៍អេឡិកត្រូនិក** សំដៅដល់ឧបករណ៍ទាំងឡាយណាដែលត្រូវបានបង្កើតឡើងសម្រាប់ធ្វើអ្វីមួយជាក់លាក់ដោយប្រើប្រាស់គ្រឿងអេឡិកត្រូនិកជាធាតុផ្សំនិងជាខួរក្បាលនៃឧបករណ៍។

## ជំពូកទី២
## លិខិតអនុញ្ញាត វិញ្ញាបនបត្រ និងអាជ្ញាបណ្ណ

### មាត្រា៥ .-

គ្មានបុគ្គលណាអាចបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន នៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ លើកលែងតែបុគ្គលនោះបានទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**)។

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (**អ.ប.គ.ព.**) ជាសេនាធិការរបស់ **ក.ប.ទ.** ក្នុង ការគ្រប់គ្រង ការផ្តល់ ការត្រួតពិនិត្យ និងការតាមដានការអនុវត្តលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ស្របតាមអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

### មាត្រា៦ .-

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតដើម្បីបំពេញប្រតិបត្តិការទៅ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងករណីដែលទីតាំងនៃប្រតិបត្តិការស្ថិតក្នុងដែនសមត្ថកិច្ចនៃមន្ទីរនោះ ដូចតទៅ៖

ក- ការលក់គ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ ដូចដែលមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ

ខ- ការរៀបចំព្រឹត្តិការណ៍ពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ

គ- ប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

### មាត្រា៧ .-

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រដើម្បីបំពេញប្រតិបត្តិការទៅ **អ.ប.គ.ព.** ដូចតទៅ៖

ក- ការទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់ និង/ឬចែកចាយគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ

ខ- ការទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឬឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

គ- ការផលិត ការផ្គុំ ឬការដំឡើងគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិកត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ

ឃ- ការនាំចូល/នាំចេញ ឬការចែកចាយគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិចត្រូនិកដែលបំពាក់បច្ចេក-វិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរ

ង- សេវាអនឡាញ

ច- ការផ្តល់សេវាប្រឹក្សានិងសេវាបច្ចេកទេសផ្នែកបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានដោយយកកម្រៃ ឬ

ឆ- ប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា៨ .-**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណដើម្បីបំពេញប្រតិបត្តិការទៅ **អ.ប.គ.ព.** ដូចតទៅ៖

ក- ការផលិតឬការផ្គុំគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឧបករណ៍អេឡិចត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬសូហ្វវែរជាលក្ខណៈឧស្សាហកម្ម

ខ- ការបង្កើតនិងធ្វើអាជីវកម្មមជ្ឈមណ្ឌលទិន្នន័យ

គ- ការបង្កើតសួនឧស្សាហកម្មបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬ

ឃ- ប្រតិបត្តិការផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

## ជំពូកទី៣

## លក្ខខណ្ឌនៃការស្នើសុំនិងការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា៩ .-**

បុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាត ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ជារូបវន្តបុគ្គលឬនីតិបុគ្គលស្ថិតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង

ខ- លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា១០ .-**

បុគ្គលដែលមានបំណងស្នើសុំវិញ្ញាបនបត្រឬអាជ្ញាបណ្ណ ត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

ក- ជារូបវន្តបុគ្គលឬនីតិបុគ្គលស្ថិតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

ខ- មានបច្ចេកវិទ្យានិងធនធានមនុស្សគ្រប់គ្រាន់តាមប្រភេទនៃប្រតិបត្តិការ ស្របតាមការកំណត់របស់ **ក.ប.ទ.** និង

គ- លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា១១ .-**

បុគ្គលដែលមានបំណងស្នើសុំអាជ្ញាបណ្ណ ត្រូវបំពេញលក្ខខណ្ឌបន្ថែមដូចខាងក្រោម៖

ក- មានរចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនដែលកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ និងភារកិច្ចដែលអាចធានាបាននូវគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងអភិបាលកិច្ចសាជីវកម្មល្អ

ខ- មានគម្រោងវិនិយោគផ្នែកធុរកិច្ចនិងផ្នែកបច្ចេកទេសច្បាស់លាស់

គ- តម្កល់ប្រាក់ធានា និងបង់កម្រៃសម្រាប់ដាក់ពាក្យស្នើសុំ ស្របតាមការកំណត់របស់ **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង

ឃ- លក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

## ជំពូកទី៤

## នីតិវិធីនៃការស្នើសុំនិងការផ្ដល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

### ផ្នែកទី១

### នីតិវិធីនៃការស្នើសុំនិងការផ្ដល់លិខិតអនុញ្ញាតនិងវិញ្ញាបនបត្រ

**មាត្រា១២ .-**

បុគ្គលដែលមានបំណងបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំមក **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ទៅតាមទម្រង់បែបបទ និងលក្ខខណ្ឌដែលកំណត់ដោយ **ក.ប.ទ.** ព្រមទាំងភ្ជាប់នូវឯកសារដូចខាងក្រោម៖

ក- ពាក្យស្នើសុំលិខិតអនុញ្ញាត ដែលកំណត់ដោយ **ក.ប.ទ.**

ខ- ឯកសារថតចម្លងបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលមានការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមពីអាជ្ញាធរមានសមត្ថកិច្ច និង

គ- ឯកសារឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា១៣ .-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំមក **អ.ប.គ.ព.** ទៅតាមទម្រង់បែបបទ និងលក្ខខណ្ឌដែលកំណត់ដោយ **ក.ប.ទ.** ព្រមទាំងភ្ជាប់នូវឯកសារដូចខាងក្រោម៖

ក- ពាក្យស្នើសុំវិញ្ញាបនបត្រ ដែលកំណត់ដោយ **ក.ប.ទ.**

ខ- ឯកសារថតចម្លងបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលមានការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមពីអាជ្ញាធរមានសមត្ថកិច្ច និង

គ- ឯកសារឬព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា១៤ .-**

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារគាំទ្រ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំ។

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្ដល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធពិនិត្យពាក្យស្នើសុំនោះរហូតដល់បុគ្គលដាក់ពាក្យស្នើសុំបានផ្ដល់ព័ត៌មានគ្រប់គ្រាន់។

**មាត្រា១៥.-**

ក្រោយពីពិនិត្យឃើញថា បុគ្គលដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌនិងមានឯកសារគាំទ្រត្រឹមត្រូវនិងពេញលេញ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវសម្រេចផ្តល់លិខិតអនុញ្ញាតឬវិញ្ញាបនបត្រជូនបុគ្គលដាក់ពាក្យស្នើសុំក្នុងរយៈពេលយ៉ាងយូរ ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ។

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចបដិសេធការផ្តល់លិខិតអនុញ្ញាតឬវិញ្ញាបនបត្រដល់បុគ្គលដាក់ពាក្យស្នើសុំ ដោយបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ។ បុគ្គលដាក់ពាក្យស្នើសុំអាចតវ៉ាមក **គ.ប.ឆ.** ចំពោះសេចក្តីសម្រេចបដិសេធរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីសម្រេចបដិសេធនេះ។ សេចក្តីសម្រេចរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **គ.ប.ឆ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្តឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **គ.ប.ឆ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **គ.ប.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលកំណត់នេះ។

**មាត្រា១៦.-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៦ និងមាត្រា៧ នៃអនុក្រឹត្យនេះ ក្រោយទទួលបានលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ តទៅហៅថា "**បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**"។

លិខិតអនុញ្ញាតមានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត លើកលែងតែចំណុច (ខ) នៃមាត្រា៦ នៃអនុក្រឹត្យនេះ។

វិញ្ញាបនបត្រមានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រ។

លិខិតអនុញ្ញាតឬវិញ្ញាបនបត្រអាចបន្តសាជាថ្មីបាន លុះណាតែបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន បានដាក់ពាក្យស្នើសុំបន្តទៅ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងអំឡុងពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃមុនពេលអស់សុពលភាព។ ទម្រង់នៃពាក្យស្នើសុំបន្តលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ ត្រូវកំណត់ដោយ **គ.ប.ឆ.**។

ក្នុងករណីខកខានមិនបានដាក់ពាក្យស្នើសុំបន្តក្នុងអំឡុងពេលដូចកំណត់ក្នុងកថាខណ្ឌទី២ ខាងលើ បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានត្រូវស្នើសុំលិខិតអនុញ្ញាតឬវិញ្ញាបនបត្រជាថ្មី ស្របតាមលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំនិងការផ្តល់លិខិតអនុញ្ញាតនិងវិញ្ញាបនបត្រ ដែលកំណត់ក្នុងអនុក្រឹត្យនេះ។

## ផ្នែកទី២
## នីតិវិធីនៃការស្នើសុំនិងការផ្តល់អាជ្ញាបណ្ណ

**មាត្រា១៧.-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុងមាត្រា៨ នៃអនុក្រឹត្យនេះ ត្រូវស្នើសុំមក **អ.ប.គ.ព.** ទៅតាមទម្រង់បែបបទនិងលក្ខខណ្ឌដែលកំណត់ដោយ **គ.ប.ឆ.** ព្រមទាំងភ្ជាប់នូវឯកសារដូចខាងក្រោម៖

ក- ពាក្យស្នើសុំអាជ្ញាបណ្ណ ដែលកំណត់ដោយ **ក.ប.ឆ.**

ខ- គម្រោងវិនិយោគផ្នែកធុរកិច្ចនិងផ្នែកបច្ចេកទេសសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ដោយរួមបញ្ចូលទាំងកាលបរិច្ឆេទចាប់ផ្តើមធ្វើប្រតិបត្តិការនិងសកម្មភាពដែលពាក់ព័ន្ធផ្សេងៗ

គ- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិងលក្ខន្តិកៈក្រុមហ៊ុន

ឃ- ព័ត៌មានអំពីរចនាសម្ព័ន្ធម្ចាស់ហ៊ុន ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងនៃបុគ្គលដាក់ពាក្យស្នើសុំ

ង- ឯកសារថតចម្លងបញ្ជាក់ពីអត្តសញ្ញាណរបស់បុគ្គលដាក់ពាក្យស្នើសុំ ដែលមានការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមពីអាជ្ញាធរមានសមត្ថកិច្ច និង

ច- ឯកសារឬព័ត៌មានផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ឆ.**។

**មាត្រា១៨.-**

**អ.ប.គ.ព.** ត្រូវពិនិត្យពាក្យស្នើសុំនិងឯកសារគាំទ្រផ្សេងៗទៀត ក្នុងរយៈពេលមិនលើសពី ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានពាក្យស្នើសុំអាជ្ញាបណ្ណ។

**អ.ប.គ.ព.** អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចបដិសេធពិនិត្យពាក្យស្នើសុំនោះរហូតដល់បុគ្គលដាក់ពាក្យស្នើសុំបានផ្តល់ព័ត៌មានគ្រប់គ្រាន់។

**មាត្រា១៩.-**

ក្រោយពីពិនិត្យឃើញថា បុគ្គលដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌនិងមានឯកសារភ្ជាប់ត្រឹមត្រូវនិងពេញលេញ **អ.ប.គ.ព.** ត្រូវស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រី **ក.ប.ឆ.** ដើម្បីចេញអាជ្ញាបណ្ណ ដល់បុគ្គលដាក់ពាក្យស្នើសុំក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ។

**អ.ប.គ.ព.** អាចស្នើសុំគោលការណ៍ពីរដ្ឋមន្ត្រី **ក.ប.ឆ.** ដើម្បីចេញសេចក្តីសម្រេចបដិសេធការផ្តល់អាជ្ញាបណ្ណដល់បុគ្គលដាក់ពាក្យស្នើសុំ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់។ បុគ្គលដាក់ពាក្យស្នើសុំអាចតវ៉ាមក **ក.ប.ឆ.** ចំពោះសេចក្តីសម្រេចបដិសេធក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសេចក្តីសម្រេចបដិសេធនេះ។ សេចក្តីសម្រេចបដិសេធត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **ក.ប.ឆ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្តឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **ក.ប.ឆ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **ក.ប.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលកំណត់នេះ។

**មាត្រា២០.-**

បុគ្គលដែលមានបំណងធ្វើប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដូចមានកំណត់ក្នុង មាត្រា៨ នៃអនុក្រឹត្យនេះ ក្រោយទទួលបានអាជ្ញាបណ្ណ តទៅហៅថា "**ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន**"។

អាជ្ញាបណ្ណមានសុពលភាព ១៥ (ដប់ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណអាចបន្តសាជាថ្មីបាន លុះណាតែប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានបានដាក់ពាក្យស្នើសុំបន្តមក **អ.ប.គ.ព.** ក្នុងអំឡុងពេលយ៉ាងតិច ០៦ (ប្រាំមួយ) ខែ មុនពេលអស់សុពលភាព។ ទម្រង់នៃពាក្យស្នើសុំបន្តអាជ្ញាបណ្ណ ត្រូវកំណត់ដោយ **គ.ប.ឌ.**។

ក្នុងករណីខកខានមិនបានជូនដំណឹងក្នុងអំឡុងពេលដូចកំណត់ក្នុងកថាខណ្ឌទី២ ខាងលើ ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានត្រូវស្នើសុំអាជ្ញាបណ្ណជាថ្មី ស្របតាមលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំនិងការផ្តល់អាជ្ញាបណ្ណដែលកំណត់ក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៥

## ការព្យួរនិងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

### ផ្នែកទី១

### មូលហេតុនៃការព្យួរនិងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

**មាត្រា២១ .-**

លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវបានព្យួរក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការស្នើសុំពីប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ខ- សេចក្តីត្រូវការជាក់ស្តែងទាក់ទងនឹងការរក្សាសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងការពារជាតិ

គ- ការខកខានមិនបានបង់កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ក្នុងរយៈពេល ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទត្រូវបង់

ឃ- ការខកខានបំពេញកាតព្វកិច្ចរបស់ខ្លួនណាមួយដែលកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ទោះបីជាបានទទួលលិខិតជូនដំណឹងជាបន្តបន្ទាប់គ្នាចំនួន ០៣ (បី) លើកពី **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

ង- ស្ថានភាពបច្ចេកទេសឬហិរញ្ញវត្ថុទន់ខ្សោយឬការចាប់ផ្តើមបើកនីតិវិធីក្ស័យធន ស្របតាមការសម្រេចរបស់តុលាការ ឬ

ច- មូលហេតុផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២២ .-**

លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវបានដកហូតក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ លើសពីរយៈពេល ០១ (មួយ) ឆ្នាំ

ខ- ប្រតិបត្តិការប៉ះពាល់អវិជ្ជមានដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងការពារជាតិ

គ- ការទទួលបានលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដោយក្លែងឯកសារឬព័ត៌មាន

ឃ- ការបន្តធ្វើប្រតិបត្តិការក្នុងអំឡុងពេលព្យួរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

ង- ត្រូវបានប្រកាសក្ស័យធនដោយតុលាការ ឬ

ច- មូលហេតុផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ផ្នែកទី២
## នីតិវិធីនៃការព្យួរនិងការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

**មាត្រា២៣ ._**

ក្រោយពិនិត្យឃើញថា មានមូលហេតុណាមួយដូចបានកំណត់ក្នុងមាត្រា២១ ឬមាត្រា២២ នៃអនុក្រឹត្យនេះ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចសម្រេចព្យួរឬដកហូតលិខិតអនុញ្ញាតឬវិញ្ញាបនបត្រ។

**អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ អាចព្យួរឬដកហូតលិខិតអនុញ្ញាត ឬវិញ្ញាបនបត្ររបស់បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ។

លិខិតអនុញ្ញាតឬវិញ្ញាបនបត្រ អាចត្រូវបានព្យួរសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ ហើយអាចពន្យារពេលនៃការព្យួរនេះរហូតដល់ ០១ (មួយ) ឆ្នាំ។ ហួសពីរយៈពេលនេះ លិខិតអនុញ្ញាតឬវិញ្ញាបនបត្រ ត្រូវក្លាយជាកម្មវត្ថុនៃការដកហូត។

បុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាចតវ៉ាមក **ក.ប.ឆ.** ចំពោះសេចក្តីសម្រេចរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលសេចក្តីសម្រេចនេះ។ សេចក្តីសម្រេចរបស់ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបិទផ្លូវតវ៉ាក្នុងករណីដែលបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **ក.ប.ឆ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្ដឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **ក.ប.ឆ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **ក.ប.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលកំណត់នេះ។

**មាត្រា២៤ ._**

ក្រោយពីពិនិត្យឃើញថា មានមូលហេតុណាមួយដូចបានកំណត់ក្នុងមាត្រា២១ និងមាត្រា២២ នៃអនុក្រឹត្យនេះ **ក.ប.ឆ.** អាចសម្រេចព្យួរឬដកហូតអាជ្ញាបណ្ណ។

**ក.ប.ឆ.** អាចព្យួរឬដកហូតអាជ្ញាបណ្ណរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដោយបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ។

អាជ្ញាបណ្ណអាចត្រូវបានព្យួរសម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ ហើយអាចពន្យារហូតដល់ ០១ (មួយ) ឆ្នាំ។ ហួសពីរយៈពេលនេះ អាជ្ញាបណ្ណ ត្រូវក្លាយជាកម្មវត្ថុនៃការដកហូត។

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានអាចតវ៉ាមក **ក.ប.ឆ.** ចំពោះសេចក្តីសម្រេចព្យួរឬដកហូតអាជ្ញាបណ្ណ ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសេចក្តីសម្រេចនេះ។ សេចក្តីសម្រេចរបស់ **ក.ប.ឆ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមិនបានតវ៉ាក្នុងរយៈពេលកំណត់នេះ។

ក្នុងករណីទទួលបានពាក្យស្នើសុំតវ៉ា **គ.ប.ទ.** ត្រូវសម្រេចលើពាក្យស្នើសុំតវ៉ានេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំតវ៉ា។ បុគ្គលដាក់ពាក្យស្នើសុំតវ៉ាអាចប្តឹងទៅតុលាការមានសមត្ថកិច្ចលើការសម្រេចរបស់ **គ.ប.ទ.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចលើពាក្យស្នើសុំតវ៉ា។ ការសម្រេចរបស់ **គ.ប.ទ.** ត្រូវបិទផ្លូវតវ៉ា ក្នុងករណីដែលបុគ្គលដាក់ពាក្យស្នើសុំតវ៉ាមិនបានដាក់ពាក្យបណ្តឹងក្នុងរយៈពេលកំណត់នេះ។

## ជំពូកទី៦

## ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ឬការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងការដាក់ប្រាតិភោគ

**មាត្រា២៥.-**

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ការផ្ទេរតាមកិច្ចសន្យា សន្តតិកម្ម ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ឬការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវគោរពតាមនីតិវិធីដូចគ្នាទៅនឹងការផ្តល់លិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងនីតិវិធីដែលមានចែងក្នុងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ក្នុងករណីប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានបំណងចង់បញ្ឈប់ប្រតិបត្តិការរបស់ខ្លួន ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននោះ ត្រូវជូនព័ត៌មានជាលាយលក្ខណ៍អក្សរទៅ **អ.ទ.ក.ក.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ចំពោះលិខិតអនុញ្ញាត យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនបញ្ចប់ប្រតិបត្តិការដោយបញ្ជាក់អំពីមូលហេតុនៃការបញ្ចប់ប្រតិបត្តិការ។

**គ.ប.ទ.** អាចតម្រូវឱ្យប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អនុវត្តកាតព្វកិច្ចមួយឬច្រើន មុននឹងបញ្ឈប់ប្រតិបត្តិការរបស់ខ្លួន។

## ជំពូកទី៧

## សិទ្ធិនិងកាតព្វកិច្ចរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

**មាត្រា២៦.-**

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានសិទ្ធិដូចខាងក្រោម៖

ក- ធ្វើប្រតិបត្តិការដែលបានស្នើសុំ

ខ- ដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

គ- ស្នើសុំប្តូរលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ

ឃ- ស្នើសុំកែប្រែគម្រោងវិនិយោគផ្នែកធុរកិច្ចនិងផ្នែកបច្ចេកទេស និង

ង-   សិទ្ធិផ្សេងទៀតដែលកំណត់ក្នុងអនុក្រឹត្យនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**មាត្រា២៧ .-**

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មានកាតព្វកិច្ចដូចខាងក្រោម៖

ក-   អនុវត្តទៅតាមលក្ខខណ្ឌទាំងឡាយដែលត្រូវបានកំណត់នៅក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និងអនុក្រឹត្យនេះនិងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត

ខ-   បង់កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និង/ឬកម្រៃផ្សេងទៀត

គ-   ផ្តល់ព័ត៌មានអំពីការផ្លាស់ប្តូរទីតាំង មក **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

ឃ-   ផ្តល់ព័ត៌មានអំពីការបញ្ឈប់ប្រតិបត្តិការ មក **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

ង-   ផ្តល់ទិន្នន័យនិងស្ថិតិពាក់ព័ន្ធនឹងប្រតិបត្តិការនិងហិរញ្ញវត្ថុ

ច-   ការពារព័ត៌មានឯកជន សន្តិសុខ និងសុវត្ថិភាពនៃការប្រើប្រាស់សេវាបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឆ-   បំពេញប្រតិបត្តិការស្របតាមគោលការណ៍ប្រកួតប្រជែងដោយស្មោះត្រង់ សេរី ស្មើភាព និងប្រកបដោយប្រសិទ្ធភាព

ជ-   ចូលរួមអនុវត្តតាមការណែនាំរបស់ **ក.ប.ទ.**

ឈ-   ហាមបើកអាជីវកម្មដែលមានលក្ខណៈខុសច្បាប់

ញ-   កាតព្វកិច្ចផ្សេងទៀតតាមការកំណត់របស់ **ក.ប.ទ.**។

បន្ថែមលើកាតព្វកិច្ចដែលបានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានត្រូវផ្តល់ឯកសារអំពីការគ្រប់គ្រងថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ដោយសវនករឯករាជ្យដែលទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងព័ត៌មានពុំមែនហិរញ្ញវត្ថុ ជារៀងរាល់ឆ្នាំសារពើពន្ធ មក **ក.ប.ទ.**។

**មាត្រា២៨ .-**

កម្រៃលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ និង/ឬកម្រៃផ្សេងទៀត និងនីតិវិធីនៃការបង់កម្រៃ ត្រូវកំណត់ដោយប្រកាសរួមរវាង **ក.ប.ទ.** និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៨

## ទោសប្បញ្ញត្តិ

**មាត្រា២៩ .-**

ក្រោយពេលផ្តល់វិញ្ញាបនបត្រឬអាជ្ញាបណ្ណក្រោមអនុក្រឹត្យនេះ ប្រសិនបើពិនិត្យឃើញថាប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន មិនអនុវត្តតាមលក្ខខណ្ឌណាមួយនៃវិញ្ញាបនបត្រឬអាជ្ញាបណ្ណ ឬលក្ខខណ្ឌណាមួយដែលកំណត់ដោយអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **ក.ប.ទ.** អាចចាត់វិធានការជាអាទិ៍ ដូចខាងក្រោម៖

ក-   ដឹកនាំកែតម្រូវប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឱ្យអនុវត្តតាមលក្ខខណ្ឌឬលក្ខខណ្ឌបន្ថែម

ខ-   បង្អាក់ការនាំចេញឬការនាំចូលគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

គ- បង្កកគណនីរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

ឃ- ដាក់កំហិតលើវិញ្ញាបនបត្រឬអាជ្ញាបណ្ណ

ង- ព្យួរវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណរហូតដល់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន គោរពពេញលេញតាមលក្ខខណ្ឌ ឬលក្ខខណ្ឌបន្ថែម

ច- ជ្រើសរើសនិងផ្តល់អំណាចដល់បុគ្គលដែលមានសមត្ថកិច្ចសមស្រប ដើម្បីពិនិត្យមើលសកម្មភាពអាជីវកម្ម ឬសកម្មភាពពាក់ព័ន្ធផ្សេងទៀតរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ទៅ **ក.ប.ទ.** តាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យាជាមួយ **ក.ប.ទ.**

ឆ- ដាក់កំហិត ឬបញ្ឈប់សកម្មភាពជាក់លាក់ ឬទូទៅរបស់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ទោះបីសកម្មភាពកាពទាំងនោះបានធ្វើឡើងស្រប ឬមិនស្របតាមលក្ខខណ្ឌនៃវិញ្ញាបនបត្រ ឬអាជ្ញាបណ្ណក៏ដោយ

ជ- ចាត់វិធានការផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

**ក.ប.ទ.** អាចចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១ លុះត្រាតែបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន អំពីមូលហេតុនៃការចាត់វិធានការនេះ និងបានផ្តល់ឱកាសឱ្យប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ឬបុគ្គលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានធ្វើការពន្យល់។

**មាត្រា៣០.-**

ការពិន័យអន្តរការណ៍ចំពោះបទល្មើសក្នុងវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាសមត្ថកិច្ចរបស់ **ក.ប.ទ.**។

**មាត្រា៣១.-**

ត្រូវពិន័យអន្តរការណ៍ ចំពោះការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា៦ នៃអនុក្រឹត្យនេះ ដោយគ្មានលិខិតអនុញ្ញាតពី **ក.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ ចំនួនទឹកប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៣ ០០០ ០០០ (បីលាន) រៀល។
- នីតិបុគ្គល៖ ចំនួនទឹកប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល។

**មាត្រា៣២.-**

ត្រូវពិន័យអន្តរការណ៍ ចំពោះការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យនេះ ដោយគ្មានវិញ្ញាបនបត្រពី **ក.ប.គ.ព.** ដូចខាងក្រោម៖

- រូបវន្តបុគ្គលៈ ចំនួនទឹកប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។
- នីតិបុគ្គលៈ ចំនួនទឹកប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

**មាត្រា៣៣ .-**

ការធ្វើប្រតិបត្តិការដូចមានចែងក្នុងមាត្រា៨ នៃអនុក្រឹត្យនេះ ដោយគ្មានអាជ្ញាបណ្ណពី **ក.ប.ឆ.** ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ដូចខាងក្រោមៈ

- រូបវន្តបុគ្គលៈ ចំនួនទឹកប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១៥ ០០០ ០០០ (ដប់ប្រាំលាន) រៀល។
- នីតិបុគ្គលៈ ចំនួនទឹកប្រាក់ពី ៥០ ០០០ ០០០ (ហាសិបលាន) រៀល ទៅ ១៥០ ០០០ ០០០ (មួយរយហាសិបលាន) រៀល។

**មាត្រា៣៤ .-**

ប្រតិបត្តិករបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ដែលមិនបានផ្តល់ឯកសារអំពីការគ្រប់គ្រងថ្លៃដើម របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ព្រមទាំងព័ត៌មានពុំមែនហិរញ្ញវត្ថុ មក **ក.ប.ឆ.** ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ ដូចមានកំណត់ក្នុងមាត្រា២៧ នៃអនុក្រឹត្យនេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ២០ ០០០ ០០០ (ម្ភៃលាន) រៀល ទៅ ៦០ ០០០ ០០០ (ហុកសិបលាន) រៀល។

**មាត្រា៣៥ .-**

បុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣១ មាត្រា៣២ មាត្រា៣៣ និងមាត្រា៣៤ នៃអនុក្រឹត្យនេះ ត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលបានទទួលសេចក្តីសម្រេចពិន័យ។

ក្នុងករណីជនល្មើស មិនបានបង់ប្រាក់ពិន័យតាមការកំណត់ដូចកថាខណ្ឌទី១ ខាងលើ **ក.ប.ឆ.** ត្រូវរៀបចំសំណុំឯកសារបញ្ជូនទៅអយ្យការអមសាលាដំបូង។

លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ឆ.** ។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .-**

ក្នុងរយៈពេល០១ (មួយ) ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខាលើអនុក្រឹត្យនេះ បុគ្គលដែលកំពុងបំពេញប្រតិបត្តិការ លើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានទាំងអស់ ត្រូវមកបំពេញទម្រង់បែបបទនៅ **អ.ប.គ.ព.** ឬមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីសុំការអនុញ្ញាតស្របតាមលក្ខខណ្ឌទាំងឡាយនៃអនុក្រឹត្យនេះ ព្រមទាំងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា៣៧ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា៣៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធភ្ជាប់អនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី ២១... ខែកក្កដា ឆ្នាំ២០១៧

## គ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័រ និងឧបករណ៍អេឡិចត្រូនិកដែលបំពាក់បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

| ល.រ | ប្រភេទនៃឧបករណ៍ (Type) |
|---|---|
| ១ | Computer |
| ២ | Keyboard |
| ៣ | MIDI Keyboard |
| ៤ | Mouse |
| ៥ | Motherboard |
| ៦ | Joystick |
| ៧ | Game Pad |
| ៨ | Scanner |
| ៩ | Printer |
| ១០ | Photocopy machine |
| ១១ | Microphone |
| ១២ | Speaker |
| ១៣ | Analog/ Digital/ IP Camera |
| ១៤ | Camcorder |
| ១៥ | Monitor/ Touch Screen |
| ១៦ | LCD/ LED Projector and LED Display |
| ១៧ | Smart TV |
| ១៨ | Internal/ External Hard drive |
| ១៩ | Floppy Disk/ CD/ DVD Reader/ Writer |
| ២០ | Memory Stick, Flash Drive... |
| ២១ | Media Card Reader |
| ២២ | PCI / PCI Express/ AGP Card |
| ២៣ | Open Hardware/ SDR Device |
| ២៤ | Hub, Switch, Router, Firewall |

២៥ Tracking Device ( GPS, Beacon, Smart Tag )

២៦ Electronic Lock, Smart Key...

២៧ Alarm Security Devices for Intrusion, Fire, CCTV...

២៨ House Appliance Remote Control

២៩ Storage ( NAS, SAN .. etc )

៣០ POS and ATM Machine

៣១ Video Conference Equipment

៣២ Test Equipment such as Multimeter, Function Generator, Oscilloscope, Data Logger...

៣៣ IP STB/ Android STB/ Apple TV Box

៣៤ DVR, NVR ..